**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន**
**និង សង្គ្រោះជនពិការដោយសារមីន**

លេខៈ ___✓___ / អន / អជម / ២០២៥

# សេចក្តីថ្លែងការណ៍

## របស់អាជ្ញាធរមីន ឆ្លើយតបការចោទប្រកាន់គ្មានមូលដ្ឋានរបស់ថៃអំពីការដាក់មីនថ្មី

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សូមធ្វើសេចក្តីថ្លែងការណ៍ ពាក់ព័ន្ធនឹងឧប្បត្តិហេតុផ្ទុះមីនកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ នៅក្បែរប្រាសាទតាក្របី និងការចោទប្រកាន់ជាបន្តបន្ទាប់របស់យោធាថៃ។ ក្នុងឧប្បត្តិហេតុខាងលើ ទាហានថៃម្នាក់បានដើរជាន់មីននៅក្នុងតំបន់ព្រំដែន ហើយរងរបួសដាច់ប្រអប់ជើងខាងស្តាំ ហើយយោធាថៃបានចោទប្រកាន់ថាកម្ពុជាបានរំលោភលើបទឈប់បាញ់ និងអនុសញ្ញាអូតាវ៉ា ដោយកម្ពុជាបានដាក់មីនថ្មីធ្វើពីប្លាស្ទិក ដែលមិនអាចរកឃើញដោយឧបករណ៍រាវមីនស្តង់ដារ។

អាជ្ញាធរមីន សូមសម្តែងនូវការសោកស្តាយចំពោះទាហានដែលរងគ្រោះដោយសារមីន និងសូមជូនពរឱ្យជាសះស្បើយយ៉ាងឆាប់រហ័ស ក៏ប៉ុន្តែកម្ពុជាក៏សូមបដិសេធយ៉ាងដាច់ខាតចំពោះការចោទប្រកាន់ដែលថា កម្ពុជាបានដាក់មីនថ្មី ដោយការចោទប្រកាន់នេះមិនមានការស៊ើបអង្កេតត្រឹមត្រូវ ឬមានភស្តុតាងច្បាស់លាស់។ កម្ពុជាប្តេជ្ញាគោរពតាមបទឈប់បាញ់ និងបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជារដ្ឋភាគីអនុសញ្ញាអូតាវ៉ា ចាប់តាំងពីឆ្នាំ២០០០ ដោយដាច់ខាតមិនប្រើប្រាស់មីនប្រឆាំងមនុស្ស។ កម្ពុជាមិនបានប្រើប្រាស់ ផលិត ឬដាក់មីនថ្មីឡើយ ចាប់តាំងពីអនុសញ្ញាចូលជាធរមានសម្រាប់កម្ពុជា។

តំបន់ដែលឧប្បត្តិហេតុកើតឡើង ស្ថិតនៅតាមបណ្តោយព្រំដែនក្បែរប្រាសាទតាក្របី ដែលជាតំបន់មានមីនច្រើន បន្សល់ទុកពីសម័យសង្គ្រាម ជាច្រើនទសវត្សរ៍មកហើយ។ ក្នុងអំឡុងសង្គ្រាមស៊ីវិល និងរបបខ្មែរក្រហម មីនរាប់លានគ្រាប់ត្រូវបានដាក់នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា រួមទាំងមីនធ្វើពីផ្លាស្ទិកផងដែរ ដែលមីនប្រភេទនេះ មានសារធាតុលោហៈតិចតួចណាស់ ពិបាកក្នុងការរកឃើញដោយប្រើប្រាស់ឧបករណ៍រាវមីនស្តង់ដារ។ ប្រតិបត្តិករបោសសម្អាតមីនកម្ពុជាដែលមានជំនាញច្បាស់លាស់ ធ្លាប់រកឃើញនិងកម្ទេចមីនប្រភេទនេះជាច្រើននៅតាមបណ្តោយព្រំដែន អស់រយៈពេលជាច្រើនឆ្នាំមកហើយ និងបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសកម្មភាពមីនកម្ពុជា។ ការដែលលើកឡើងថាមីននេះធ្វើពីផ្លាស្ទិក និងពិបាកក្នុងការរាវរក គឺពិតជាស្របទៅនឹងកំណត់ត្រានៃការបោសសម្អាតមីនរបស់កម្ពុជាក្នុងតំបន់នេះ ហើយវាមិនមែនជាមីនថ្មីនោះទេ។ តំបន់ក្បែរប្រាសាទតាក្របី ដែលយោធាថៃបានអះអាងថាមានឧប្បត្តិហេតុផ្ទុះមីន គឺជាតំបន់ដែលមានមីនក្រាស់ និងហានិភ័យខ្ពស់។ ឧប្បត្តិហេតុនេះ គឺពិតជា

បង្កឡើងដោយសារគ្រាប់មីនចាស់ មិនមែនជាគ្រាប់មីនថ្មីឡើយ ហើយទាមទារឱ្យយើងផ្តោតសំខាន់លើការបោសសម្អាតមីនមនុស្សធម៌ ជាជាងការចោទប្រកាន់ដោយគ្មានការពិត។

កម្ពុជា សម្រេចបានសមិទ្ធផលធំធេងក្នុងការបោសសម្អាតមីន ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់បច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី នៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ នៅតែបន្តរងគ្រោះធ្ងន់ធ្ងរដោយសារមីន ជាពិសេសតំបន់ដែលមិនមែនជាអាទិភាពសម្រាប់ធ្វើការបោសសម្អាត ជូនប្រជាពលរដ្ឋរស់នៅ និងបម្រើដល់សេដ្ឋកិច្ច-សង្គម តែតំបន់នោះត្រូវបានដាក់ស្លាកសញ្ញាមីន និងធ្វើបច្ចុប្បភាពចម្ការមីនជាប្រចាំ។

ពាក់ព័ន្ធនឹងឧប្បត្តិហេតុនេះ អាជ្ញាធរមីន សូមអំពាវនាវឱ្យរក្សាភាពស្ងប់ស្ងៀម និងបន្តកិច្ចសហប្រតិបត្តិការចៀសវាងការបង្កើនកំដៅ។ កម្ពុជាសូមជំរុញឱ្យភាគីថៃ បង្ហាញនូវភស្តុតាង និងអនុញ្ញាតឱ្យមានស៊ើបអង្កេតឯករាជ្យ។ កម្ពុជា-ថៃ គឺជារដ្ឋភាគីអនុសញ្ញាអូតាវ៉ា និងមានកាតព្វកិច្ចរួមក្នុងការបោសសម្អាតមីនចាស់ និងការពារមិនឱ្យមានការប្រើប្រាស់មីនថ្មី។ កម្ពុជា ស្វាគមន៍ចំពោះយន្តការទ្វេភាគីដែលមានស្រាប់ រួមទាំងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ និងគំនិតផ្តួចផ្តើមបោសសម្អាតមីនមនុស្សធម៌។

ជាចុងក្រោយ កម្ពុជាបញ្ជាក់ជាថ្មីថា កម្ពុជាមិនបានប្រើប្រាស់ ហើយនឹងមិនប្រើប្រាស់មីនប្រឆាំងមនុស្សឡើយ និងនៅតែប្តេជ្ញាអនុវត្តតាមអនុសញ្ញាអូតាវ៉ា និងបទឈប់បាញ់។ កម្ពុជានឹងនៅតែបន្តកិច្ចសហប្រតិបត្តិការ និងការបោសសម្អាតមីន ដែលបន្សល់ទុកពីសម័យសង្គ្រាម។ កម្ពុជាសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធ ចូលរួមដោះស្រាយបញ្ហានេះ ដោយទទួលខុសត្រូវ រក្សាឱ្យបានសន្តិភាពនៅតាមតំបន់ព្រំដែន និងធានាឱ្យបានសុវត្ថិភាពរបស់ប្រជាជនទាំងពីរ។ កម្ពុជាសូមជំរុញឱ្យភាគីថៃអនុវត្តតាមបទឈប់បាញ់ និងមិនមានចល័តកងទ័ពនៅក្នុងតំបន់នោះ អំឡុងពេលនៃបទឈប់បាញ់។

ថ្ងៃពុធ ៤កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២៥

KINGDOM OF CAMBODIA

Nation Religion King

THE ROYAL GOVERNMENT

Cambodian Mine Action
and Victim Assistance Authority

File No:____√__/VP/CMAA/2025

**CMAA Statement in Response to Thailand's Baseless Allegation on New Mine-Planting**

The Cambodian Mine Action and Victim Assistance Authority (CMAA) issues the following statement regarding the August 27, 2025 landmine incident near Ta Krabey Temple and subsequent allegations made by the Royal Thai Army. A Thai soldier was severely injured after stepping on a landmine in the border area, losing part of his lower right leg. The Royal Thai Army has accused Cambodia of violating the ceasefire agreement and the Ottawa Treaty by allegedly planting new "plastic" landmines undetectable by standard mine detectors.

The CMAA expresses its sincere sympathy to the injured soldier and wishes him a full recovery. However, we firmly reject the accusation that Cambodian forces have laid new landmines. These claims lack clear investigation or credible evidence. Cambodia remains fully committed to the ceasefire and to its obligations as a State Party to the Ottawa Convention since 2000, maintaining a zero-tolerance policy on anti-personnel mines. Cambodia has never used, produced, or deployed new landmines since the treaty entered into force.

The area in question lies along the border near Ta Krabey Temple, which has for decades been heavily contaminated by landmines from past conflicts. During the civil war and the Khmer Rouge period, millions of mines were laid across Cambodia's northwest frontier, including in this very sector. The area is long known to be highly contaminated by various types of anti-personnel mines, including those with plastic casings. These devices contain very little metal, making them difficult to detect with standard mine detectors. Cambodian well-trained demining teams have been encountering and clearing these types of mines across border provinces for years, and they are well documented in our mine action records. The fact that a plastic-cased mine escaped routine detection is therefore entirely consistent with the long-standing, legacy contamination in this area, not evidence of new planting. The area near Ta Krabey Temple, specifically cited by the Thai side, is well known as a high-risk zone where remnants of war remain scattered. This unfortunate incident is far more plausibly the result of such a pre-existing mine than any recent activity, underscoring the urgent need for continued humanitarian clearance rather than premature or unfounded accusations.

Cambodia has made significant achievements in mine action since the 1990s. Yet the Cambodia–Thailand border remains contaminated, especially in remote areas prioritized after villages and farmland. Warning signs have been placed in frontier areas, and maps are continuously updated.

In light of this incident, CMAA calls for calm and cooperation, not escalation. We urge our Thai counterparts to share any evidence, which must be subject to independent verification. Both countries are States Parties to the Ottawa Convention and share a duty to prevent new use and clear old mines. We welcome the existing bilateral mechanisms, including Regional Border Committee meetings, and remain open to coordinated humanitarian demining initiatives.

In conclusion, Cambodia reiterates that it has not used new landmines and will never do so, and remains steadfast in its commitment to the Ottawa Convention and the ceasefire. Our focus will continue to be humanitarian demining and cooperation to eliminate the remaining threat from past wars. We appeal to all stakeholders to resolve this matter responsibly, uphold peace along the border, and ensure the safety of both Cambodian and Thai citizens. We urge Thailand to strictly adhere to the ceasefire agreement by refraining from any troop movement during this period.

Phnom Penh, 27 August 2025

Address: New Building, St.273, Corner 516, Sangkat Toul Sangker, Khan Russey Keo, Phnom Penh. Tel: 023 885 941, 023 881 492